Australian Government
Australian Taxation Office

# របៀបត្រៀមខ្លួនដើម្បីធ្វើរបាយការណ៍ទូទាត់ពន្ធរបស់អ្នក។

ការទូទាត់ពន្ធរបស់អ្នកមាន 3 ជំហាន៖
ប្រមូល រៀបចំ និងដាក់ពាក្យទូទាត់ពន្ធ។

## 1. ប្រមូល

ប្រមូលព័ត៌មានដែលអ្នកនឹងត្រូវការ។ អនុវត្តតាមបញ្ជីត្រួតពិនិត្យខាងក្រោម ដើម្បីប្រាកដថាអ្នកដាក់បញ្ចូលព័ត៌មានត្រឹមត្រូវនៅក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នក។

អ្នកត្រូវការព័ត៌មានសម្រាប់ឆ្នាំប្រាក់ចំណូលចាប់ពីថ្ងៃទី 1 ខែកក្កដា ដល់ថ្ងៃទី 30 ខែមិថុនា។

## 2. រៀបចំ

សម្រេចចិត្តពីរបៀបដែលអ្នកនឹងធ្វើរបាយការណ៍ទូទាត់ពន្ធរបស់អ្នក។

ប្រសិនបើអ្នកកំពុងធ្វើរបាយការណ៍ទូទាត់ពន្ធផ្ទាល់ខ្លួនរបស់អ្នក អ្នកអាចដាក់ពាក្យតាមអនឡាន ដោយប្រើ myTax (ជាភាសាអង់គ្លេស) ឬប្រើរបាយការណ៍ទូទាត់ពន្ធជាក្រដាស (ជាភាសាអង់គ្លេស)។
ដើម្បីប្រើ myTax អ្នកនឹងត្រូវការអត្តសញ្ញាណសម្គាល់អ្នកប្រើ myGov និងពាក្យសម្ងាត់របស់អ្នក។
ប្រសិនបើអ្នកមិនមានគណនី myGov ទេ អ្នកអាចបង្កើតគណនីមួយ ហើយភ្ជាប់ទៅ ATO នៅ my.gov.au (ជាភាសាអង់គ្លេស)។

ប្រសិនបើអ្នកកំពុងប្រើភ្នាក់ងារពន្ធដែលបានចុះឈ្មោះក្នុងបញ្ជីដើម្បីដាក់ពាក្យ អ្នកគួរតែធ្វើការណាត់ជួបដើម្បីពិភាក្សាជាមួយពួកគេ។

DE-20789-3-ENG

តើព័ត៌មានអ្វីខ្លះដែលខ្ញុំត្រូវការសម្រាប់របាយការណ៍ទូទាត់ពន្ធរបស់ខ្ញុំ?

អ្នកនឹងត្រូវការ៖

- ☐ លេខបញ្ជីពន្ធ (TFN)
- ☐ ព័ត៌មានលម្អិតអំពីគណនីធនាគារ (លេខសម្គាល់សាខាធនាគារ (BSB) និងលេខគណនី) ក្នុងករណីដែលអ្នកជំពាក់លុយដែលត្រូវសង
- ☐ ព័ត៌មានលម្អិតអំពីប្រាក់ចំណូលរបស់អ្នក៖
    - ☐ របាយការណ៍ប្រាក់ចំណូលពីនិយោជករបស់អ្នកទាំងអស់ ឬនៅក្នុងគណនី myGov របស់អ្នក។
    - ☐ របាយការណ៍សង្ខេបស្តីពីប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាល (ឧទាហរណ៍ Centrelink)
    - ☐ ប្រាក់ចំណូលពីការវិនិយោគ (ឧទាហរណ៍ ការប្រាក់នៅក្នុងរបាយការណ៍ធនាគារ របាយការណ៍ភាគលាភនៃភាគហ៊ុន)
    - ☐ ប្រាក់ចំណូលពីបរទេស (ឧទាហរណ៍ការងារ ឬការវិនិយោគក្រៅប្រទេស)
    - ☐ ប្រាក់ចំណូលផ្សេងទៀត (ឧទាហរណ៍ការងារយកសាច់ប្រាក់ ទ្រព្យសម្បត្តិជួល)
- ☐ ព័ត៌មានលម្អិតអំពីប្រាក់ចំណាយដែលអាចកាត់កងពីពន្ធ និងការចំណាយរបស់អ្នក៖
    - ☐ កំណត់ត្រាសម្រាប់ការចំណាយទាក់ទងនឹងការងារ (ឧទាហរណ៍ បង្កាន់ដៃ សៀវភៅ កត់ត្រាភស្តុតាងស្តីពីការងារពីផ្ទះ )
    - ☐ បង្កាន់ដៃសម្រាប់អំណោយ ឬការបរិច្ចាគដែលអ្នកបានធ្វើទៅអង្គការសប្បុរសធម៌ដែលមានសិទ្ធិ និងអង្គការផ្សេងទៀត។
- ☐ ព័ត៌មានលម្អិតអំពីប្តីប្រពន្ធ (រៀបការ ឬនៅជាមួយគ្នាមិនបានរៀបការ) រួមទាំងប្រាក់ចំណូលជាប់ពន្ធរបស់ពួកគេ។

## 3. ដាក់ពាក្យទូទាត់ពន្ធ

ដាក់ពាក្យទូទាត់ពន្ធរបស់អ្នកឱ្យបានមុនកាលបរិច្ឆេទកំណត់។

ប្រសិនបើអ្នកកំពុងធ្វើរបាយការណ៍ទូទាត់ពន្ធផ្ទាល់ខ្លួនរបស់អ្នក អ្នកត្រូវការដាក់ពាក្យឱ្យបានមុនថ្ងៃទី 31 ខែតុលា ជារៀងរាល់ឆ្នាំ។

ប្រសិនបើភ្នាក់ងារពន្ធដែលបានចុះឈ្មោះក្នុងបញ្ជីកំពុងជួយអ្នក អ្នកត្រូវចាប់ផ្តើមធ្វើការជាមួយពួកគេឱ្យបានមុនថ្ងៃទី 31 ខែតុលា។

ភ្នាក់ងារពន្ធដែលបានចុះក្នុងបញ្ជីគឺជាមនុស្សដែលត្រូវបានអនុញ្ញាតឱ្យយកថ្លៃសេវាកម្មដើម្បីដាក់ពាក្យទូទាត់ពន្ធរបស់អ្នក។ អ្នកអាចពិនិត្យមើលថាតើភ្នាក់ងារពន្ធរបស់អ្នកត្រូវបានចុះឈ្មោះក្នុងបញ្ជីនៅ tpb.gov.au (ជាភាសាអង់គ្លេស)។

### តើពេលណាជាពេលវេលាដ៏ល្អបំផុតដើម្បីដាក់ពាក្យទូទាត់ពន្ធ?

និយោជក ធនាគារ និងអាជីវកម្មផ្សេងទៀតផ្តល់ឱ្យយើងនូវព័ត៌មានលម្អិតអំពីប្រាក់ចំណូលដែលពួកគេបង់ទៅឱ្យអ្នកបង់ពន្ធ។ ប្រសិនបើអ្នករង់ចាំរហូតដល់ចុងខែកក្កដា យើងដាក់បញ្ចូលព័ត៌មានលម្អិតទាំងនេះនៅក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នកសម្រាប់អ្នក។ នេះធ្វើឱ្យការដាក់ពាក្យទូទាត់ពន្ធរបស់អ្នកកាន់តែលឿន និងងាយស្រួលផង។

ប្រសិនបើអ្នកកំពុងធ្វើរបាយការណ៍ទូទាត់ពន្ធផ្ទាល់ខ្លួនរបស់អ្នក អ្នកមានរយៈពេលចាប់ពីថ្ងៃទី 1 ខែកក្កដា ដល់ថ្ងៃទី 31 ខែតុលា ដើម្បីដាក់ពាក្យ។

### ការរក្សាកំណត់ត្រាល្អធ្វើឱ្យពេលទូទាត់ពន្ធកាន់តែងាយស្រួល

ការរក្សាកំណត់ត្រាចាប់ពីដើមឆ្នាំប្រាក់ចំណូលនីមួយៗនឹងធ្វើឱ្យវាកាន់តែងាយស្រួលក្នុងការធ្វើរបាយការណ៍ទូទាត់ពន្ធរបស់អ្នក។ រក្សាសន្លឹកបណ្ណប្រាក់ខែ និងបង្កាន់ដៃរបស់អ្នកសម្រាប់ប្រាក់ចំណាយដែលអាចកាត់កងពីពន្ធទាំងអស់ដែលអ្នកចង់ដាក់បញ្ចូល។ របាយការណ៍ធនាគារ (តែមួយ) ជាទូទៅមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីទាមទារប្រាក់ដែលអាចកាត់កងពីពន្ធសម្រាប់ការចំណាយទាក់ទងនឹងការងារនោះទេ។

រក្សាទុកកំណត់ត្រារបស់អ្នកនៅកន្លែងដែលមានសុវត្ថិភាព។ ឧបករណ៍ myDeductions នៅក្នុងអែបរបស់ ATO អាចជួយអ្នកបាន។ ស្វែងយល់បន្ថែមនៅ ato.gov.au/app (ជាភាសាអង់គ្លេស)។

### កន្លែងដើម្បីទទួលបានជំនួយ

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ ATO នៅ ato.gov.au/TaxTimeResources (ជាភាសាអង់គ្លេស)។

អ្នកក៏អាចនិយាយជាមួយភ្នាក់ងារពន្ធដែលបានចុះឈ្មោះក្នុងបញ្ជីសម្រាប់ជំនួយផងដែរ។

**ការប្រកាសបដិសេធទំនួលខុសត្រូវ៖** ព័ត៌មាននេះគឺជាសេចក្តីសង្ខេបទូទៅតែប៉ុណ្ណោះ ហើយមានបច្ចុប្បន្នភាពនៅថ្ងៃទី 26 ខែមីនា ឆ្នាំ 2024។ អ្នកមានសេរីភាពក្នុងការថតចម្លង កែសម្រួល កែប្រែ បញ្ជូន និងចែកចាយសម្ភារៈនេះតាមបំណងរបស់អ្នក (ប៉ុន្តែមិនមែនតាមរបៀបណាមួយដែលបង្ហាញថា ATO ឬ Commonwealth គាំទ្រអ្នក ឬសេវាកម្ម ឬផលិតផលណាមួយរបស់អ្នក)។